## សមាគមគំនិតផ្តួចផ្តើមនៃការផ្លាស់ប្តូរ

# ការបោះជំរុំយុវជនលើកទី៥

# យុវជន និងការសម្រេចចិត្តៈ ជីវិតខ្ញុំ ជម្រើសខ្ញុំ

សមាគមគំនិតផ្តួចផ្តើមនៃការផ្លាស់ប្តូរ គឺជាសមាគមអ្នកស្ម័គ្រចិត្ត បង្កើតឡើងដោយយុវជនមួយក្រុមដែលមានឆន្ទៈធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងប្រទេសកម្ពុជា និងនៅលើពិភពលោក ដោយចាប់ផ្តើមពីបុគ្គលម្នាក់ៗ។ សមាគមនេះ ត្រូវបានទទួលស្គាល់ជាផ្លូវការពីក្រសួងមហាផ្ទៃ ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ។

ការបោះជំរុំយុវជន គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពនានា ដែលសមាគមបានប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ។ សមាគម បានរៀបចំការបោះជំរុំយុវជនលើកទី១ ក្នុងឆ្នាំ២០០៧ នៅខេត្តមណ្ឌលគីរីក្រោមប្រធានបទ*រួមគ្នាបង្កើតវប្បធម៌សន្តិភាព*។ លើកទី២នៅខេត្តកោះកុងក្រោមប្រធានបទ *រៀបចំអនាគតរបស់យើងនៅថ្ងៃនេះ*។ លើកទី៣នៅខេត្តប៉ៃលិន ក្រោមប្រធានបទ *យុវជន និងការចូលរួមក្នុងសង្គម*។ ការបោះជំរុំលើកទី៤នៅខេត្តសៀមរាប ក្រោមប្រធានបទ *យុវជន និងសេរីភាព*។

ក្នុងឆ្នាំ២០១១នេះ សមាគមគំនិតផ្តួចផ្តើមនៃការផ្លាស់ប្តូរ រួមសហការជាមួយបណ្តាញពលរដ្ឋដើម្បីអភិវឌ្ឍន៍សង្គម (CAN) នឹងរៀបចំការបោះជំរុំយុវជនលើកទី៥ ក្រោមប្រធានបទ *យុវជន និងការសម្រេចចិត្តៈ ជីវិតខ្ញុំ ជម្រើសខ្ញុំ*។

☞ តាមរយៈការចូលរួមក្នុងកម្មវិធីបោះជំរុំនេះ អ្នកចូលរួមនឹងទទួលបានៈ

☑ ចំណេះដឹងទាក់ទងនឹងជម្រើសជីវិត និងការទទួលខុសត្រូវ
☑ ការប្រើប្រាស់ជីវិតឲ្យមានប្រយោជន៍
☑ ការស្គាល់ពីបណ្តាញពលរដ្ឋដើម្បីអភិវឌ្ឍន៍សង្គម និងសមាគមគំនិតផ្តួចផ្តើមនៃការផ្លាស់ប្តូរ ព្រមទាំងគុណតម្លៃទាំង៤ ក្នុងការដឹកនាំជីវិត
☑ ការបង្កើនចំណងមិត្តភាព និងផ្លាស់ប្តូរបទពិសោធន៍ជីវិតដោយស្មោះត្រង់
☑ ការបង្កើនភាពក្លាហាន
☑ ការផ្លាស់ប្តូរការគិត និងឥរិយាបថ ដើម្បីខ្លួនឯង គ្រួសារ និងសង្គម
☑ ឱកាសក្នុងការបញ្ចេញនូវភាពប៉ិនប្រសព្វរបស់ខ្លួនតាមរយៈការធ្វើការងារជាក្រុម

យើងខ្ញុំជឿជាក់ថា អ្នកនឹងត្រលប់មកវិញ ជាមួយនឹងអនុស្សាវរីយ៍ដែលមិនអាចបំភ្លេចបាន។ សូមអញ្ជើញចូលរួមជាមួយយើងក្នុងការបោះជំរុំយុវជលើកទី៥ នេះ។

☞លក្ខខណ្ឌចូលរួមៈ

☑ មានអាយុចាប់ពី ១៦ ដល់ ២៦ឆ្នាំ
☑ មានសីលធម៌ ភាពរួសរាយ និងទំនួលខុសត្រូវខ្ពស់ចំពោះខ្លួនឯង
☑ មានឆន្ទៈចង់ចេះដឹង ឬមានចំណេះដឹងស្តីអំពីកិច្ចការសង្គម ឬធ្លាប់បានចូលរួមក្នុងកិច្ចការសង្គមនានា
☑ មានសេចក្តីក្លាហាន ហ៊ានបញ្ចេញមតិ និងចែករំលែកបទពិសោធន៍ជាមួយយុវជនដទៃទៀត
☑ ចូលរួមគ្រប់សកម្មភាពទាំងឡាយដែលមាននៅក្នុងការបោះជំរុំ

☑ ចូលរួមវិភាគទានចំនួន ១២ដុល្លារ ក្នុងករណីដែលអ្នកត្រូវបានជ្រើសរើស (ប៉ុន្តែសម្រាប់ យុវជនដែលមិនមាន លទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ប្រាក់ ប៉ុន្តែមានឆន្ទៈខ្ពស់ក្នុងការចូលរួម គណៈកម្មការនឹងពិចារណាចំពោះការបន្ថយ រឺលើកលែងការបង់វិភាគទាននេះ)។

យុវជនដែលចាប់អារម្មណ៍ចង់ចូលរួមក្នុងការបោះជំរុំនេះ សូមមកទទួលនិងដាក់ពាក្យនៅ*សមាគមគំនិតផ្តួចផ្តើមនៃការផ្លាស់ប្តូរ* ផ្ទះលេខ ៤០ ផ្លូវលេខ៣៩BT សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ឬ៤០ ផ្លូវលេខ៣៩BT សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ឬ *បណ្តាញពលរដ្ឋដើម្បីអភិវឌ្ឍសង្គម* ផ្ទះលេខ ៣១៦D ផ្លូវ ១៥០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ឬផ្ញើអ៊ីមែលទៅកាន់ youthcamp.ica@gmail.com ឲ្យបានមុនថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ឬទំនាក់ទំនងមកគណៈកម្មការរៀបចំការបោះជំរុំ៖

1- កញ្ញា គាំង ស្រីពៅ ០១៧ ៤៩៤ ២៦២
2- លោក សេង ចាន់ណា ០៩០ ៩៧៧ ០៧៩
3- កញ្ញា ស្រឿន ដាលីន ០៩៧ ៥១១ ៦១ ៦២
4- លោក ផល គន្ធា ០៦៧ ៦១៧ ២៨៣
5- កញ្ញា នាងសុវ៉ាត់ចាន់ដារី ០៩៨ ៨៦៣ ៣៩៦

*ផុតកំណត់ទទួលពាក្យនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង ៥ល្ងាច។*